World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៧៩

របាយការណ៍គិតត្រឹមថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២២ ម៉ោង១០:00នាទីព្រឹក

## ស្ថានការណ៍សង្ខេបសំខាន់ៗ (១០ ដល់ ២៣ មករា ឆ្នាំ២០២២)

- ករណីវិជ្ជមានវីរុសកូវីដ-១៩ សរុបចំនួន ៤៣០ និងមិនមានករណីស្លាប់ ត្រូវបានរាយការណ៍នៅក្នុងរយៈពេល១៤ថ្ងៃចុងក្រោយនេះ។ នេះមានន័យថាមានការកើនឡើងចំនួន ១៥០ភាគរយនៃចំនួនករណីបើប្រៀបធៀបទៅនឹងរយៈពេល១៤ថ្ងៃកន្លងទៅ។ ក្នុងចំណោម ៤៣០ ករណីនោះ ៥១ភាគរយជាករណីនាំចូល និងចំនួន ៤៩ភាគរយជាករណីឆ្លងក្នុងស្រុក។
- ករណីសរុបទាំងអស់ចំនួន ១២១.០៦៦ ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ៣.០១៥ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងចំណោមនោះ ១១៧.២៣២ ករណីបានជាសះស្បើយ។ ករណីនាំចូលពីក្រៅប្រទេសសរុបមានចំនួន ២០.២៦៨ ឬស្មើនឹង ១៦.៧ ភាគរយនៃករណីជំងឺកូវីដ-១៩ ទាំងអស់។
- ចាប់តាំងពីខែមករា ឆ្នាំ២០២០ មក បុគ្គលសរុបចំនួន ១.៧៩៤.៤៣៥នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Real-Time Polymerase Chain Reaction, RT-PCR) ដោយមានអត្រាវិជ្ជមានក្នុងកម្រិត ៤.៨ ភាគរយ។ ជាសរុប គិតត្រឹមថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២២ ចំនួនតេស្ត ២.៥០១.៣០៤ ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍។
- **ការតាមដានជំងឺ:** គិតត្រឹមថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ ករណីវិជ្ជមានវីរុសកូវីដ-១៩ប្រភេទបំប្លែងខ្លួនថ្មីអូមីក្រុងសរុបចំនួន៦២៥ ត្រូវបានរកឃើញនៅកម្ពុជាដែលនៅក្នុងនោះ ២១៤ករណីជាករណីឆ្លងក្នុងសហគមន៍។ អង្គការសុខភាពពិភពលោក បន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួងសុខាភិបាលនៅក្នុងការអនុវត្តយុទ្ធសាស្ត្រតាមដានជំងឺសម្រាប់ជំងឺរាតត្បាតកូវីដ-១៩ ដើម្បីធានឱ្យមានការរកឃើញករណីបានឆាប់រហ័ស និងឆ្លើយតបចំគោលដៅ និងអនុវត្តប្រព័ន្ធតាមដាន និងរាយការណ៍អំពីការគោរពតាមវិធានការសុខភាពសាធារណៈ និងវិធានការសង្គម។
- **មន្ទីរពិសោធន៍:** អង្គការសុខភាពពិភពលោកកំពុងផ្តល់ការប្រឹក្សាផ្នែកបច្ចេកទេសដល់ក្រសួងសុខាភិបាលស្តីពីយុទ្ធសាស្ត្រប្រមូលសំណាកសម្រាប់ការតាមដានសេណ្ឋមសាស្ត្រចំពោះវីរុសកូវីដ-១៩ រួមទាំងការដាក់បញ្ចូលការស្វែងរកមេរោគកូវីដ-១៩បំប្លែងខ្លួនថ្មីអូមីក្រុងទៅក្នុងលំហូរការងារតាមដានជំងឺសេណ្ឋមសាស្ត្របច្ចុប្បន្ន។ វិទ្យាស្ថានសុខភាពសាធារណៈ បានសហការជាមួយនឹងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា អង្គការសុខភាពពិភពលោក និងដៃគូនៅក្នុងការអនុវត្តកម្មវិធីធានាគុណភាពវីរុសកូវីដ-១៩ (SARS-CoV-2 External Quality Assurance) ដើម្បីធានាគុណភាពតេស្តនៅមន្ទីរពិសោធន៍រកវីរុសកូវីដ-១៩ទាំងអស់។
- **ការចាក់វ៉ាក់សាំងកូវីដ-១៩:**
  - គិតត្រឹមថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជាទទួលបានវ៉ាក់សាំងកូវីដ-១៩ចំនួន ៤៣.៤៩២.៥៩០ ដូស
    - ចំនួន ២៨.៥០០.០០០ដូស ឬស្មើនឹង ៦៦ ភាគរយ សម្រាប់វ៉ាក់សាំងស៊ីណូវ៉ាក់ និង វ៉ាក់សាំងស៊ីណូហ្វាម តាមរយៈការបញ្ជាទិញដោយរាជរដ្ឋាភិបាលកម្ពុជាពីសាធារណរដ្ឋប្រជាមានិត្យចិន
    - ចំនួន ១១.០៦៥.៥៧០ដូស ឬស្មើនឹង ២៥ ភាគរយតាមរយៈជំនួយ (៨.៣០០.០០០ដូសវ៉ាក់សាំងស៊ីណូវ៉ាក់ និង វ៉ាក់សាំងស៊ីណូហ្វាម ជាជំនួយរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិត្យចិន ចំនួន ៤១៥.០៤០ដូសវ៉ាក់សាំង AstraZeneca ជាជំនួយរបស់ រដ្ឋាភិបាលនៃចក្រភពអង់គ្លេស និងចំនួន ២.៣៥០.៥៣០ ដូសនៃវ៉ាក់សាំង Pfizer-BioNTech ជាជំនួយរបស់ប្រទេសអូស្ត្រាលី)។
    - ចំនួន ៣.៩២៧.៥៩០ដូស ឬស្មើនឹង ៩ ភាគរយនៃវ៉ាក់សាំង AstraZeneca, Johnson & Johnson, Moderna និង Sinovac ទទួលបានតាមរយៈជំនួយពីមជ្ឈមណ្ឌលកូវ៉ាក់ (ដែលក្នុងនោះរួមមានជំនួយពីរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលសហរដ្ឋអាមេរិក រដ្ឋាភិបាលស៊ុយអែត និងរដ្ឋាភិបាលប្រទេសហូល្លង់)។
  - សកម្មភាពចាក់វ៉ាក់សាំង កំពុងបន្តតាមរយៈការអនុវត្តយុទ្ធសាស្ត្រចាក់វ៉ាក់សាំងដល់អ្នកដែលពិបាកចូលទៅដល់ឱ្យពួកគាត់ទទួលបានការចាក់វ៉ាក់សាំងពេញលេញជាពិសេសក្នុងចំណោមក្រុមប្រជាជនងាយរងគ្រោះ (ដូចជាមនុស្សវ័យចាស់ អ្នកដែលមានជំងឺប្រចាំកាយ ស្រ្តីមានផ្ទៃពោះ ស្រ្តីកំពុងបំបៅដោះកូន អ្នកមានផ្ទុកវីរុស និងមានជំងឺអេដស៍ អ្នកមានពិការភាព និងជនទេសន្តរប្រវេសន៍) និងអ្នកដែលបានជាសះស្បើយពីជំងឺកូវីដ-១៩។ សកម្មភាពទាំងនេះ ត្រូវបានអនុវត្តនៅៈ ទី១ កន្លែងចាក់វ៉ាក់សាំងដែលមាននៅតាមមូលដ្ឋានសុខា ភិបាល (មន្ទីរពេទ្យជាតិ មន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែក) ទី២ ការចាក់វ៉ាក់សាំងចល័ត និងទី៣ការចាក់វ៉ាក់សាំងចល័តដែលត្រូវបានដាក់បញ្ចូលជាមួយនឹងការចុះចាក់វ៉ាកសាំងជាប្រចាំនៅតាមមូលដ្ឋាន។
  - ការគាំទ្រពីអង្គការសុខភាពពិភពលោក
    - ផ្តល់ការគាំទ្រដល់កម្មវិធីថ្នាក់ជាតិផ្តល់ថ្នាំបង្ការ ដើម្បីរៀបចំផែនការសម្រាប់សកម្មភាពចាក់វ៉ាក់សាំងកូវីដ-១៩ចំនួនពីរជុំនៅអំឡុងត្រីមាសទីមួយនិងត្រីមាសទីពីរនៃឆ្នាំ២០២២។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- ផ្តល់ការគាំទ្រដល់កម្មវិធីថ្នាក់ជាតិផ្តល់ថ្នាំបង្ការដើម្បីធ្វើបច្ចុប្បន្នភាពពីផែនការជាតិដាក់ពង្រាយ និងចាក់ថ្នាំបង្ការសម្រាប់វ៉ាក់សាំងកូវីដ-១៩។
- ការវិភាគ និងរបាយការណ៍អំពីការចាក់វ៉ាក់សាំង និងទិន្នន័យអំពីហេតុការណ៍កើតឡើងក្រោយពេលចាក់វ៉ាក់សាំង រួមទាំងការចែករំលែកព័ត៌មានដល់ភាគីពាក់ព័ន្ធ។
- ការតាមដានទីវាល និងពិនិត្យមើលមណ្ឌលចាក់វ៉ាក់សាំងកូវីដ-១៩នៅខេត្តសៀមរាប និងរាជធានីភ្នំពេញ ដើម្បីធានាឱ្យមានការចាក់វ៉ាក់សាំងសម្រាប់ប្រជាពលរដ្ឋងាយរងគ្រោះ(ដូចជាមនុស្សវ័យចំណាស់ អ្នកដែលមានជំងឺប្រចាំកាយ ស្ត្រីមានផ្ទៃពោះ ស្ត្រីកំពុងបំបៅដោះកូន អ្នកមានផ្ទុកវីរុស និងមានជំងឺអេដស៍ និងអ្នកដែលបានជាសះស្បើយពីជំងឺកូវីដ-១៩)។

## ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍

- ការរៀបចំសារសំខាន់ៗសម្រាប់ផ្សព្វផ្សាយតាមទូរទស្សន៍ និងវិទ្យុអំពីវិធានការសុខភាពសាធារណៈ និងសង្គមក្នុងអំឡុងពេល និងក្រោយបុណ្យចូលឆ្នាំចិន។
- មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព កំពុងពិនិត្យឡើងវិញនូវសកម្មភាពចូលរួមរបស់សហគមន៍ជុំបន្ទាប់នៅក្នុងខេត្តចំនួន ៩ រួមទាំងការបណ្តុះបណ្តាលអំពីជំនាញប្រាស្រ័យទាក់ទង និងការឆ្លើយតបចំពោះសារ និងព័ត៌មានមិនពិតនៅថ្នាក់មូលដ្ឋាន។

## អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ

- រាជរដ្ឋាភិបាលកម្ពុជា បានចេញសារាចរស្តីពីការជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ និងការពង្រឹងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ជាពិសេសមេរោគបំប្លែងខ្លួនថ្មីប្រភេទអូមីក្រុង។
- រាជរដ្ឋាភិបាលកម្ពុជា បានចេញសេចក្តីប្រកាសព័ត៌មានស្តីពីនីតិវិធីសម្រាប់បង្ការ និងទប់ស្កាត់ការចម្លង និងរីករាលដាលនៃវីរុសកូវីដ-១៩បំប្លែងថ្មីប្រភេទអូមីក្រុងសម្រាប់អ្នកដំណើរចូលមកប្រទេសកម្ពុជាទាំងអស់ ហើយអនុញ្ញាតឱ្យអ្នកជំងឺកូវីដ-១៩ប្រភេទអូមីក្រុងទាំងជនបរទេស និងជនជាតិខ្មែរ អាចទទួលការថែទាំ និងព្យាបាលនៅតាមផ្ទះដូចករណីអ្នកជំងឺកូវីដ-១៩ប្រភេទអាល់ហ្វា ឬដែលតាដែរ។

## អន្តរាគមន៍ និងការផ្តល់សេវាសុខភាព

- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល បានសិក្សាអំពីថាតើសេវាប្រភេទណាមួយទទួលរងផលប៉ះពាល់ដោយការរាតត្បាតខ្លាំងជាងគេ និងមូលហេតុ ដើម្បីរៀបចំអន្តរគមន៍ឆ្លើយតបសមស្របដើម្បីបន្តសេវាសុខភាពសារវ័ន្តអំឡុងពេលការរាតត្បាតជាសាកលនៃជំងឺកូវីដ-១៩។ នាយកដ្ឋានមន្ទីរពេទ្យ បានរៀបចំកិច្ចប្រជុំអនឡាញលើកទីបួនកាលពីថ្ងៃទី ២១ ខែមករា ឆ្នាំ២០២២ ដោយមានការចូលរួមពីឯកឧត្តមប្រធានមន្ទីរសុខាភិបាលខេត្ត នាយកមន្ទីរពេទ្យខេត្ត និងនាយកនាយករងមន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែកទាំង៩ទៀតនៃខេត្តបន្ទាយមានជ័យ។
- នាយកដ្ឋានមន្ទីរពេទ្យ និងអង្គការសុខភាពពិភពលោក បានរៀបចំកិច្ចពិភាក្សាតាមអនឡាញមួយស្តីពីលក្ខខណ្ឌក្រោយកូវីដ-១៩ កាលពីថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២២។ វេទិការអនឡាញនោះ មានគោលបំណងពង្រឹងសម្ថភាពអ្នកអាជីពផ្នែកគ្លីនិកក្នុងការគ្រប់គ្រងករណីដែលមានបញ្ហានានាក្រោយជាសះស្បើយពីជំងឺកូវីដ-១៩ ដោយយល់ដឹងពីបទពិសោធន៍ពីបរទេស។ មានការធ្វើបទបង្ហាញដោយក្រុមការងារគ្រប់គ្រងផ្នែកគ្លីនិករបស់អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិកខាងលិច។ មានការចូលរួមពីបុគ្គលិកថែទាំសុខភាពជាង១០០នាក់ និងមានវគ្គឆ្លើយសំណួរបន្ទាប់ពីការធ្វើបទបង្ហាញរួច។



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៧៩

របាយការណ៍គិតត្រឹមថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២២ ម៉ោង១០:00នាទីព្រឹក

### ក្រាហ្វិកទី១. ខ្សែកោងអេពីដេមីសាស្ត្រនៃករណីជំងឺកូវីដ-១៩ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ២០២១-២០២២*




*ចាប់ពីថ្ងៃ ៣០ ខែកញ្ញាឆ្នាំ២០២១មក មានតែលទ្ធផលតេស្តវីរុសកូវីដ-១៩ បញ្ជាក់ដោយ PCR ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ជាចំនួនករណីឆ្លងផ្លូវការ

### តារាងទី១. តារាងសង្ខេបអំពីសូចនាករកូវីដ-១៩

| បច្ចុប្បន្នភាពអេពីដេមីសាស្ត្រអំពីកូវីដ-១៩ | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
|---|---|---|---|---|
| | 14,671<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល១៤ថ្ងៃចុងក្រោយ | 430<br>ករណីវិជ្ជមានថ្មីក្នុងពេល១៤ថ្ងៃចុងក្រោយ | 0<br>ករណីស្លាប់ក្នុងពេល១៤ថ្ងៃចុងក្រោយ | 220<br>ករណីនាំចូលក្នុងពេល១៤ថ្ងៃចុងក្រោយ |
| | 2,501,304<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 121,066<br>ករណីសរុប | 3,015<br>ករណីស្លាប់សរុប | 380<br>ករណីនាំចូលពីបរទេសក្នុងរយៈពេល២៨ថ្ងៃចុងក្រោយ |

| ការផ្តល់សេវាសុខភាពអំពីកូវីដ-១៩ | | | |
|---|---|---|---|
| | 79<br>ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | 145<br>ចំនួនមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ | 1,626<br>ចំនួនគ្រែដែលមាននៅមន្ទីរពេទ្យ និង មណ្ឌលព្យាបាល |

ប្រភពទិន្នន័យ៖ រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ (ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០២១)



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## តារាងទី២. ការវាយតម្លៃ[1]អំពីដំណាក់កាលចម្លងតាមខេត្តនីមួយៗ

| ដំណាក់កាលចម្លង | ខេត្ត |
|---|---|
| **ដំណាក់កាលចម្លងទី២** | រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តព្រះវិហារ ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ |
| **ដំណាក់កាលចម្លងទី១** | ខេត្តកោះកុង ខេត្តកែប ខេត្តក្រចេះ ខេត្តប៉ៃលិន ខេត្តពោធិសាត់ ខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី |

## តារាងទី៣. យុទ្ធនាការចាក់វ៉ាក់សាំងសម្រាប់បុគ្គលិកសុខាភិបាល មនុស្សពេញវ័យ យុវវ័យ និងកុមារ

| | បុគ្គលិកសុខាភិបាល | មនុស្សពេញវ័យ | | យុវវ័យ និងកុមារ | | |
|---|---|---|---|---|---|---|
| | | អាយុចាប់ពី ៦០ឆ្នាំ | អាយុចាប់ពី ១៨ឆ្នាំ | អាយុ៥ឆ្នាំ | អាយុពី៦ឆ្នាំដល់ក្រោម ១២ឆ្នាំ | អាយុចាប់១២ឆ្នាំដល់ក្រោម ១៨ឆ្នាំ |
| | (N=43,646) | (N=1,378,688) | (N=10,000,000) | (N=304,317) | (N=1,897,382) | (N=1,827,348) |
| ចាប់ផ្តើម (2021) | 10 កុម្ភៈ | 10 កុម្ភៈ | 10 កុម្ភៈ | 1 វិច្ឆិកា | 17 កញ្ញា | 1 សីហា |
| **ដូសទី១** | 43,646 (100%) | 1,393,494 (101.1%) | 10,165,224 (101.7%) | 320,411 (105.3%) | 2,007,822 (105.8%) | 1,817,185 (99.4%) |
| **ដូសទី២** | 43,646 (100%) | 1,369,756 (99.4%) | 9,840,872 (98.4%) | 242,659 (79.7%) | 1,917,736 (101.1%) | 1,738,051 (95.1%) |
| **ដូសទី៣** | 4,804,821 (48.1%) | | | | | 510,206 (27.9%) |
| **ដូសទី៤** | 343,211 (3.4%) | | | | | |

[1] តំណាក់កាលចម្លងសម្រាប់ការចាត់ថ្នាក់កម្រិតថ្នាក់ក្រោមជាតិដោយអង្គការសុខភាពពិភពលោកប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី៤. អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស តាមប្រភេទវ៉ាក់សាំងកូវីដ-១៩**

| ប្រភេទវ៉ាក់សាំងកូវីដ-១៩ | Sinovac | Sinopharm | AstraZeneca (Covishield) | J&J | AstraZeneca (Vaxzevria) | Moderna | Pfizer | សរុប |
|---|---|---|---|---|---|---|---|---|
| ចំនួនករណី | 98 | 79 | 29 | 4 | 1 | 0 | 0 | 211 |
| ចំនួនដូសសរុបបានចាក់ | 21,260,506 | 7,345,559 | 323,344 | 1,053,151 | 2,238,019 | 180,903 | 281,500 | 30,209,708 |
| អត្រានៃហេតុការណ៍ក្នុងចំណោម ១០០.០០០ដូស | 0.46 | 1.08 | 8.97 | 0.38 | 0.04 | 0 | 0 | 0.65 |

**តារាងទី៥. ការអនុវត្តអន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ និងថ្ងៃលើកបម្រាមវិញ**

| អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ | ស្ថានភាពត្រួតពិនិត្យ | | | | | |
|---|---|---|---|---|---|---|
| | ថ្ងៃទី១នៃការអនុវត្ត | ថ្ងៃកែប្រែចុងក្រោយ | ការអនុវត្ត | | ត្រូវបានលើកដោយផ្នែក | ត្រូវបានលើកទាំងស្រុង |
| | | | ភូមិសាស្ត្រ (ថ្នាក់ជាតិ ឬ ថ្នាក់ក្រោមជាតិ) | ណែនាំឲ្យ ឬតម្រូវឲ្យ | លើកសម្រាប់វិស័យ/ផ្នែកខ្លះ | លើកសម្រាប់វិស័យ/ផ្នែកទាំងអស់ |
| ពាក់ម៉ាស់ការពារ អនាម័យដៃ និងផ្លូវដង្ហើម | មិនមានទេ | ១៦ សីហា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ | | មិនទាន់លើកទេ |
| បិទសាលារៀន | ១៦ មីនា ឆ្នាំ២០២០ | ១ វិច្ឆិកា ឆ្នាំ២០២១ | ថ្នាក់ជាតិ | ណែនាំឲ្យ | បានលើកហើយ | លើកបម្រាមហើយ |
| ការជួបជុំមនុស្សម្នាច្រើន | ៣ មេសា ឆ្នាំ២០២០ | ១២ វិច្ឆិកា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ | បានលើកហើយ | លើកបម្រាមហើយ |
| រឹតបន្តឹងការធ្វើដំណើរនៅក្នុងប្រទេស | ៩ មេសា ឆ្នាំ២០២០ | ២៩ កក្កដា ឆ្នាំ២០២១ | ថ្នាក់ជាតិ | ណែនាំឲ្យ | បានលើកហើយ | បានលើកហើយ |
| ការរឹតបន្តឹងលើការធ្វើដណើរអន្តរជាតិ | ២៧ មីនា ឆ្នាំ២០២០ | ០៥ ធ្នូ ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ | បានលើកហើយ | បានលើកហើយ |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## ការគាំទ្រដោយអង្គការសុខភាពពិភពលោក

អង្គការសុខភាពពិភពលោក បន្តគាំទ្រក្រសួងសុខាភិបាលនៅក្នុងវិស័យបច្ចេកទេសជាច្រើន ដូចជាផ្តល់យោបល់ផ្នែកបច្ចេកទេសជាភស្តុតាងវិទ្យាសាស្ត្រសម្រាប់បញ្ហាដែលកំពុងកើតមានដូចជាវីរុសកូវីដ-១៩បំប្លែងខ្លួនថ្មីអូមីក្រុង សកម្មភាពតាមដានជំងឺរួមទាំងការតាមដានជំងឺដោយប្រើព័ត៌មានពហុប្រភព និងយុទ្ធសាស្ត្រតាមដានជំងឺសម្រាប់ជំងឺរាតត្បាតកូវីដ-១៩ ការគាំទ្រក្នុងការពិនិត្យឡើងវិញ និងកែប្រែគោលការណែនាំបច្ចេកទេសនានា ការបង្កើត និងចែកចាយវ៉ាក់សាំង ក៏ដូចជាការធ្វើផែនការចែកចាយវ៉ាក់សាំង ហើយនិងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព (ឧទាហរណ៍ ការពង្រឹងការអនុវត្តវិធានការការពារ ការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទងអំពីសុវត្ថិភាពវ៉ាក់សាំង) ព្រមទាំងការអនុវត្តយុទ្ធសាស្ត្រស្តីពីការរស់នៅតាមបែបគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩។

## អភិក្រមយុទ្ធសាស្ត្រ

សម្រាប់ព័ត៌មានស្តីពីអភិក្រមយុទ្ធសាស្ត្រ សូមមើលរបាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ១៩ លេខមុនៗ ចេញមុនថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។

## បទពិសោធន៍ល្អៗ និងមេរៀនដែលទទួលបាន

1. **យើងត្រូវតែវិនិយោគនៅថ្ងៃទៅលើការត្រៀមខ្លួនទុកជាមុន ដើម្បីកុំឱ្យយើងមានការសោកស្តាយនៅថ្ងៃស្អែក។** ការត្រៀមខ្លួនទុកជាមុនរួចរាល់ គឺជាវិធីដ៏ល្អបំផុតក្នុងការកាត់បន្ថយផលវិបាកផ្នែកសុខភាព សេដ្ឋកិច្ច និងសង្គមឱ្យកម្រិតទាបបំផុត។ ជំងឺកូវីដ-១៩ នឹងមិនមែនជាវិបត្តិសុខភាពចុងក្រោយនោះទេ។
2. **យើងត្រូវតែកែប្រែប្រព័ន្ធសុខាភិបាលសម្រាប់ពេលអនាគត។** ប្រព័ន្ធសុខាភិបាលដែលរឹងមាំគឺជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ការគ្រប់គ្រងជំងឺកូវីដ-១៩ និងសម្រាប់ការគ្រប់គ្រងគ្រោះអាសន្នផ្នែកសុខភាពណាមួយនាពេលអនាគត។
3. **យើងត្រូវតែបង្កើតការរស់នៅតាមបែបគន្លងប្រក្រតីភាពថ្មីមួយ។** ជំងឺកូវីដ-១៩ នឹងក្លាយទៅជាជំងឺឆ្លងធម្មតាមួយ។ យើងទាំងអស់គ្នាត្រូវតែសម្របខ្លួនរស់នៅ ធ្វើការ និងទំនាក់ទំនងគ្នាទៅវិញទៅមក តាមរបៀបថ្មីមួយ ហើយនិងរស់នៅជាមួយនឹងមេរោគនេះ។

## ឯកសារយើង និងតំណរភ្ជាប់ដែលពាក់ព័ន្ធ

- គេហទំព័រក្រសួងសុខាភិបាល: គេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល
- របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក: របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់ប្រទេសកម្ពុជា។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់តំបន់:របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិកខាងលិច។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់សាកល: របាយការណ៍បច្ចុប្បន្នភាពស្តីពីកូវីដ-១៩ផ្នែកប្រតិបត្តិការ និងអេពីដេមីសាស្ត្ររបស់អង្គការសុខភាពពិភពលោកថ្នាក់សាកល។
- គោលការណែនាំរបស់អង្គការសុខភាពពិភពលោក: គោលការណែនាំសម្រាប់ប្រទេស និងបច្ចេកទេសអំពីកូវីដ-១៩ចុងក្រោយបំផុតរបស់អង្គការសុខភាពពិភពលោក។
- ក្តារព័ត៌មានឌីជីថលស្តីពីកូវីដ-១៩របស់អង្គការសុខភាពពិភពលោក: ទិន្នន័យកូវីដ-១៩កម្រិតតំបន់ និងពិភពលោកចុងក្រោយបំផុត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។